# អង្គរបុរី
## សម្លេងខ្មែរនៅបរទេស

# ការវិភាគ

## របស់ព្រះតេជព្រះគុណបណ្ឌិត ហុក-សាវណ្ណ ក្រោមប្រធានបទ សហរដ្ឋអាមេរិកគួរជួយពង្រឹងប្រជាធិបតេយ្យនិងការគោរពសិទ្ធិមនុស្សនៅប្រទេសកម្ពុជាឲ្យបានរឹងមាំ កុំឲ្យមេរៀនឆ្នាំ១៩៧០ដល់ឆ្នាំ១៩៧៥ កើតឡើងវិញ ។

website: www.hoksavann.org
ថ្ងៃទី១២ កញ្ញា ២០០៧



កាលពីឆ្នាំ១៩៧០ដល់ឆ្នាំ១៩៧៥ សហរដ្ឋអាមេរិកមិនបានជួយសាធារណរដ្ឋខ្មែរពេញដៃពេញជើង ដែលធ្វើឲ្យសាធារណរដ្ឋនេះរលំធ្លាក់លើដៃពួកកុម្មុយនិស្តដ៏កំណាច ហើយកើតបានជាវាលពិឃាតរបស់ពួកខ្មែរក្រហមឆ្នាំ១៩៧៥ដល់ឆ្នាំ១៩៧៩ ។ គេបន្ទោសសហរដ្ឋអាមេរិកដ៏ខ្លាំងបំផុត គឺនៅពេលនោះសហរដ្ឋអាមេរិកមិនបានរកសន្តិភាពជូនប្រទេសកម្ពុជាតាមមធ្យោបាយចរចាជាមួយសាធារណរដ្ឋប្រជាមានិតចិនដែលជាប្រទេសគាំទ្រខ្មែរក្រហមយ៉ាងពេញទំហឹង ដើម្បីបញ្ចប់សង្គ្រាម ធ្វើការសម្របសម្រួលគ្នាដោយសន្តិវិធី មុននឹងសហរដ្ឋអាមេរិកដកខ្លួនថយ ព្រោះសង្គ្រាមប្រទេសកម្ពុជាពាក់ព័ន្ធនឹងសហរដ្ឋអាមេរិកធ្វើសង្គ្រាមនៅប្រទេសវៀតណាម ពាក់ព័ន្ធនឹងយៀកកុងនិងយួនខាងជើង តាំងមូលដ្ឋានទ័ពលើទឹកដីខ្មែរ ពាក់ព័ន្ធនឹងអ្នកកាន់អំណាចខ្មែរ អនុញ្ញាតឲ្យទ័ពបរទេសបោះទីតាំងនៅលើទឹកដីរបស់ខ្លួនធ្វើឲ្យសង្គ្រាមឆាបឆេះមកដល់ប្រទេសកម្ពុជា ។ល។ នេះជាមេរៀនប្រវត្តិសាស្ត្រ ដែលសហរដ្ឋអាមេរិកគប្បីលើកមកសិក្សា ហើយបន្តជួយប្រទេសកម្ពុជាដ៏អភ័ព្វនេះ ឲ្យរស់រានមានជីវិតឡើងវិញ កុំឲ្យមានកំហុសជាលើកទី២ទៀត ។

តាមផែនការរបស់រដ្ឋាភិបាលសហរដ្ឋអាមេរិក ចង់ឲ្យប្រទេសក្នុងពិភពលោកកាន់របបប្រជាធិបតេយ្យ គោរពឆន្ទៈរបស់ប្រជាពលរដ្ឋ និងគោរពសិទ្ធិមនុស្ស ។ ដូច្នេះការ

ជួយប្រជាពលរដ្ឋខ្មែររបស់សហរដ្ឋអាមេរិកពេលនេះគ្មានអ្វីក្រៅពីផែនការនេះឡើយ គឺពុំមែនជួយគ្រាប់បែកគ្រាប់កាំភ្លើង ឲ្យខ្មែរយកទៅសម្លាប់គ្នា ដូចអំឡុងឆ្នាំ១៩៧០ឡើយ គឺជួយវិភាគទានបញ្ញាស្មារតី ជួយខ្មែរឲ្យស្គាល់សិទ្ធិរបស់ខ្លួន ជួយឲ្យខ្មែរគោរពសិទ្ធិគ្នា ជួយឲ្យខ្មែរចេះដឹងថា អំណាចគ្រប់យ៉ាងជាពិសេសអំណាចដឹកនាំរដ្ឋ កើតចេញមកពីប្រជាពលរដ្ឋជាដើម ។ការបណ្ដុះធនធានមនុស្សជាអាទិភាព ហើយជាការចាំបាច់សំរាប់ជនជាតិខ្មែរ សំរាប់រៀបចំសង្គមរបស់ខ្លួនឆ្ពោះទៅរកសន្តិភាពនិងវឌ្ឍនភាព ។ ធនធានមនុស្ស គឺការសិក្សាអប់រំឲ្យមានចំណេះវិជ្ជាខ្ពង់ខ្ពស់គ្រប់ផ្នែក ជាពិសេសចំណេះខាងការគោរពសិទ្ធិមនុស្ស និងរបៀបបែបបទនៃលទ្ធិប្រជាធិបតេយ្យ ។ តាមពិតព្រះពុទ្ធសាសនាបានប្រៀនប្រដៅរួចហើយ អំពីឫសគល់នៃការគោរពសិទ្ធិមនុស្ស ដូចជាព្រះអង្គមិនឲ្យមនុស្សបៀតបៀនគ្នា រហូតដល់ព្រះអង្គហាមកុំឲ្យបៀតបៀនសម្លាប់សត្វមានជីវិតទាំងអស់ទៀតផង ។ ដូច្នេះសហរដ្ឋអាមេរិកគ្រាន់តែជួយជំរុញនិងឧបត្ថម្ភបន្ថែម ដូចជាកម្មវិធីអប់រំប្រជាធិបតេយ្យតាមបែបវិជ្ជាទំនើបជាដើម ។ ជួយឧបត្ថម្ភព្រះសង្ឃព្រះពុទ្ធសាសនា ដើម្បីឲ្យលោកមានលទ្ធភាពទៅអប់រំសិស្សនិងនិស្សិតនៅតាមអាគារសិក្សាគ្រប់ភូមិសិក្សា ដើម្បីឲ្យយល់ដឹងនូវតម្លៃសីលធម៌ និងតម្លៃរបស់មនុស្សតាមមាគ៌ាព្រះពុទ្ធសាសនា ។ ការបណ្ដុះធនធានមនុស្សតាមបែបព្រះពុទ្ធសាសនាមានគុណភាពជ្រាលជ្រៅណាស់ ព្រោះព្រះពុទ្ធសាសនាជាមូលដ្ឋាននៃការគោរពសិទ្ធិមនុស្សនិងប្រជាធិបតេយ្យរួចទៅហើយ ឯជំនួយខាងក្រៅគ្រាន់តែជួយឧបត្ថម្ភ និងជួយជំរុញដើរទៅមុខបានលឿនប៉ុណ្ណោះ ។ ជំនួយខាងចំណេះចេះដឹងខាងការផ្សាយតាមវិទ្យុ ដែលសហរដ្ឋអាមេរិកបានផ្សាយពីវ៉ាស៊ីនតោនឌីស៊ី គឺវិទ្យុសម្លេងសហរដ្ឋអាមេរិក និងវិទ្យុអាស៊ីសេរី ជាជំនួយមួយយ៉ាងសំខាន់ណាស់សំរាប់ប្រទេសទន់ខ្សោយ ទាំងបញ្ញាស្មារតី ទាំងការដឹកនាំរដ្ឋ និងជីវភាពរស់នៅដូចប្រទេសកម្ពុជានេះ ។ សហរដ្ឋអាមេរិកគួរផ្ដល់អាហារូបករណ៍ឲ្យយុវជននិងយុវនារីខ្មែរ មកសិក្សានៅសហរដ្ឋអាមេរិកឲ្យបានច្រើន ដើម្បីឲ្យនិស្សិតទាំងនោះយកវិជ្ជាដែលបានរៀនចេះដឹង យកទៅបង្រៀនសិស្សនិងនិស្សិតខ្មែរបន្តទៅទៀតនៅប្រទេសកម្ពុជា ក៏ដូចជាយកវិជ្ជាទៅអនុវត្តកិច្ចការរដ្ឋ ឲ្យបានត្រឹមត្រូវតាមរបបប្រជាធិបតេយ្យ ។ សហរដ្ឋអាមេរិកគួរបញ្ឈប់បញ្ជូនជនជាតិខ្មែរខ្លះ ដែលរួចទោសហើយនៅសហរដ្ឋ ឲ្យទៅរស់នៅប្រទេសកម្ពុជាវិញ ទោះបីមានការព្រមព្រៀងហើយជាមួយរាជរដ្ឋាភិបាលខ្មែរ ក៏ដោយ ព្រោះនេះជាអំពើអមនុស្សធម៌ នាំឲ្យបែកបាក់គ្រួសារ ដែលផ្ទុយអំពីនយោបាយសហរដ្ឋអាមេរិកខាងអន្តោប្រវេសន៍ដែលបង្រួបបង្រួមគ្រួសារ ។ សំលៀកបំពាក់ដែលដឹកនាំមកពីប្រទេសកម្ពុជាមកលក់នៅសហរដ្ឋអាមេរិក គួរអនុគ្រោះពន្ធជាបន្តទៅទៀត ព្រោះនេះជាវិភាគទានរបស់សហរដ្ឋអាមេរិកជួយដល់ប្រជាពលរដ្ឋខ្មែរ ឲ្យមានការងារធ្វើបានមួយភាគក្នុងការបំបាត់ភាពក្រីក្រនៃប្រជាជនខ្មែរ ។ អំពើពុករលួយរបស់រាជការ

ខ្មែរ ជាគ្រោះថ្នាក់ធំណាស់របស់ប្រទេសកម្ពុជា សហរដ្ឋអាមេរិកអាចជួយបង្ក្រាបអំពើនេះ ដោយភ្ជាប់លក្ខខណ្ឌទៅនឹងជំនួយគ្រប់យ៉ាងរបស់សហរដ្ឋអាមេរិកដល់ប្រទេសកម្ពុជា ។

ការបណ្តុះធនធានមនុស្សតាមបែបព្រះពុទ្ធសាសនា និងតាមផ្លូវអាណាចក្រ ត្រូវប្រើពេលយូរ ប៉ុន្តែជាការចាំបាច់ត្រូវតែធ្វើ ។ ការចាំបាច់មួយទៀត ត្រូវតែធ្វើជាបន្ទាន់ក្នុងរយៈពេលខ្លី គឺការបោះឆ្នោតដោយសេរីនិងយុត្តិធម៌ក្នុងឆ្នាំ២០០៨ ដើម្បីជ្រើសរើសតំណាងរាស្ត្រ និងជ្រើសរើសអ្នកដឹកនាំខាងនីតិប្រតិបត្តិសំរាប់អាណត្តិទី៤នេះ ។ សហរដ្ឋអាមេរិកមានសមត្ថភាពអាចជួយពិនិត្យឲ្យការបោះឆ្នោតនោះ មានភាពត្រឹមត្រូវអាចទទួលយកបាន ។ ការបោះឆ្នោតតាមរបបប្រជាធិបតេយ្យនេះ ជាមធ្យោបាយសំខាន់ណាស់ជាការឆ្លុះបញ្ចាំងនូវឆន្ទៈរបស់ប្រជាពលរដ្ឋខ្មែរ ក្នុងការជ្រើសរើសអ្នកដឹកនាំរបស់ខ្លួន ហើយជាការជៀសវាងសង្គ្រាមក្នុងស្រុកផង ព្រោះគ្រប់គណបក្សទាំងអស់សុខចិត្តគោរពតាមឆន្ទៈរបស់ប្រជាពលរដ្ឋដែលជាម្ចាស់អំណាច ។ សហរដ្ឋអាមេរិកអាចជួយបង្ហាត់បង្រៀនរបៀបបោះឆ្នោតតាមរបបប្រជាធិបតេយ្យដល់ប្រជាពលរដ្ឋខ្មែរ និងជួយត្រួតពិនិត្យការបោះឆ្នោត ។ ការបោះឆ្នោតនៅប្រទេសកម្ពុជាមានវិវាទនឹងគ្នាគ្រប់អាណត្តិ ជាពិសេសគណបក្សប្រឆាំងបានចោទគណបក្សកាន់អំណាច ថាបានប្លន់ហុងឆ្នោតជាដើម ។ សហរដ្ឋអាមេរិកត្រូវប្រកាន់គោលជំហរយុត្តិធម៌ចំពោះអ្នកធ្វើល្អនិងអ្នកធ្វើអាក្រក់ ព្រោះមានសកម្មភាពខ្លះរបស់សហរដ្ឋអាមេរិក ត្រូវគេចោទថាលំអៀង ដូចជាសហរដ្ឋអាមេរិកចោទប្រធានាធិបតីប៉ាគីស្ថាន ថាជាជនផ្តាច់ការ ប៉ុន្តែក្រោយមក សហរដ្ឋអាមេរិកឈប់ចោទ ដោយសារប្រធានាធិបតីនេះធ្វើសហការជាមួយសហរដ្ឋអាមេរិក ដើម្បីវាយប្រទេសអ៊ីរ៉ាក់ ។ យ៉ាងណាមិញ សហរដ្ឋអាមេរិកធ្លាប់ចោទអ្នកដឹកនាំខ្មែរបច្ចុប្បន្ននេះ ថាជាជនផ្តាច់ការរំលោភសិទ្ធិមនុស្ស ឥឡូវនេះស្ងាត់មាត់ ដោយសាររាជរដ្ឋាភិបាលខ្មែរនេះធ្វើសហការជាមួយសហរដ្ឋអាមេរិក ក្នុងការបំបាត់ភេរវជន និងសុខចិត្តមិនបញ្ជូនទាហានអាមេរិកដែលប្រព្រឹត្តខុស ទៅឲ្យតុលាការអន្តរជាតិកាត់ទោស ។៚

❊ ❊

❊